**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង

## ស្តីពី

## ដំណោះស្រាយនៅក្រុមហ៊ុន គលរ័ ស្តារ (ខេមបូឌា) ប្រដាក់

## (COLOR STAR (CAMBODIA) PRODUCT CO., LTD)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់សាធារណជន ជាពិសេស បងប្អូនកម្មករនិយោជិតនៃក្រុមហ៊ុន **គលរ័ ស្តារ (ខេមបូឌា) ប្រដាក់ (COLOR STAR (CAMBODIA) PRODUCT CO., LTD)** ស្ថិតនៅផ្លូវ២៧២ ភូមិព្រែកជ្រៃ សង្កាត់ស្ពានថ្ម ខណ្ឌដង្កោ រាជធានីភ្នំពេញ ជ្រាបថា កាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៥ ក្រោយទទួលបានដំណឹងអំពីការតវ៉ារបស់បងប្អូនកម្មករនិយោជិតចំពោះការប្តូរទីតាំងថ្មីរបស់ក្រុមហ៊ុន ក្រសួងបានចុះសម្របសម្រួលករណីនេះ ដោយសម្រេចបានកិច្ចព្រមព្រៀងមួយគឺ ក្រុមហ៊ុននឹងធ្វើការទូទាត់ផ្តាច់កិច្ចសន្យាការងារដល់បងប្អូនកម្មករនិយោជិតដែលមិនស្ម័គ្រចិត្តទៅធ្វើការបន្តនៅទីតាំងថ្មី។ ជាក់ស្តែង នៅព្រឹកថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៥នេះ ក្រោមការសម្របសម្រួលសារជាថ្មីរបស់ក្រសួង ក្រុមហ៊ុនបានឯកភាពទូទាត់ចំនួន ៤ចំណុច ស្របទៅតាមច្បាប់ ដូចខាងក្រោម៖

១. ប្រាក់ឈ្នួលដែលមិនទាន់បានបើក

២. ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់

៣. ប្រាក់បំណាច់ជួសការជូនដំណឹងមុន

៤. ប្រាក់បំណាច់អតីតភាពការងារ។

ក្នុងន័យនេះ ក្រសួងសូមអំពាវនាវដល់បងប្អូនកម្មករនិយោជិតនៃក្រុមហ៊ុន **គលរ័ ស្តារ (ខេមបូឌា) ប្រដាក់** (COLOR STAR (CAMBODIA) PRODUCT CO., LTD) ជឿជាក់និងរង់ចាំការដោះស្រាយរបស់ក្រសួង ចៀសវាងការយកជម្រើសតវ៉ាដោយការបិទផ្លូវសាធារណៈដែលនាំឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងអាចឈានដល់ការប្រព្រឹត្តល្មើសច្បាប់ដែលជាបទល្មើសព្រហ្មទណ្ឌ។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមសាធារណជន និងបងប្អូនកម្មករនិយោជិត មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ៩រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៥

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩